

# ស្ថានទូតអូស្ត្រាលី
## ភ្នំពេញ

## សេចក្តីប្រកាសពត៌មាន
[illegible]

## ពានរង្វាន់អូស្ត្រាលី

កាលពីថ្ងៃទី១៣ ខែវិច្ឆិកា រដ្ឋាភិបាលប្រទេសអូស្ត្រាលីបានប្រកាសនូវគំនិតផ្តួចផ្តើមថ្មីមួយគឺ ពានរង្វាន់អូស្ត្រាលី ដើម្បីជាសារៈប្រយោជន៍អតិបរិមាដល់ប្រទេសអូស្ត្រាលី ចំពោះកម្មវិធីអាហារូបករណ៍ដ៏ទូលំទូលាយរបស់ខ្លួន និងដើម្បីបន្តគាំទ្រដល់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងប្រទេសអូស្ត្រាលី និងបណ្តាប្រទេសជិតខាង ។

បច្ចុប្បន្ន ប្រទេសអូស្ត្រាលីបានចំណាយជាទឹកប្រាក់ចំនួន ២00 លានដុល្លារ សំរាប់កម្មវិធីអាហាររូបករណ៍ក្នុងមួយឆ្នាំៗ ដើម្បីឧបត្ថម្ភគាំទ្រដល់និស្សិតអន្តរជាតិប្រមាណ ៥000 នាក់ អោយបានទៅសិក្សានៅប្រទេសអូស្ត្រាលី នៅគ្រប់ពេលវេលាទាំងអស់ ។

ពានរង្វាន់អូស្ត្រាលី នឹងនាំយកមកនូវកម្មវិធីអាហារូបករណ៍ទាំងអស់ អោយស្ថិតនៅក្រោមនិមិត្តសញ្ញាតែមួយដែលអាចទទួលស្គាល់បាន ជាជាងការខិតខំបង្កើតកម្មវិធីអាហារូបករណ៍តាមរយៈក្រុមមួយដោយគ្មានការសម្របសម្រួល ។ គំនិតផ្តួចផ្តើមបង្កើតពានរង្វាន់អូស្ត្រាលីនឹងធានាអោយបានថា អាហារូបករណ៍អូស្ត្រាលីត្រូវបានពង្រឹងអោយមាននិមិតសញ្ញាល្អ និងផ្តល់សារៈប្រយោជន៍ដល់ប្រទេសអូស្ត្រាលីក្នុងរយៈពេលយូរ ។

ដូចផែនការ Colombo Plan ដែលបានផ្តល់ការអប់រំសិក្សារបស់អូស្ត្រាលីទៅក្នុងតំបន់ជានិមិត្តសញ្ញាមួយដែលមានការសម្របសម្រួល និងទទួលស្គាល់ក្នុងមួយជំនាន់កន្លងទៅ ។ គំនិតផ្តួចផ្តើមពានរង្វាន់អូស្ត្រាលីនឹងបង្កើនការយល់ដឹង និងតម្លៃទៅលើកម្មវិធីស្តីពី អាហារូបករណ៍ទំនើបរបស់អូស្ត្រាលី ។

គំនិតផ្តួចផ្តើមពានរង្វាន់អូស្ត្រាលី នឹងកសាងនូវភាពជាអ្នកដឹកនាំជំនាន់ថ្មី ដោយមានទំនាក់ទំនងយ៉ាងរឹងមាំជាមួយនឹងប្រទេសអូស្ត្រាលី ។

No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

ពានរង្វាន់អូស្ត្រាលីនឹងមានចរន្តពីរៈ គឺ ចរន្តភាពជាអ្នកដឹកនាំ ដែលនឹងជ្រើសរើសយកនិស្សិតដែលមានសមត្ថភាព និងឆ្លាតវៃដើម្បីអោយមកសិក្សានៅប្រទេសអូស្ត្រាលី និងចរន្តអភិវឌ្ឍមួយដែលនឹងកសាងសមត្ថភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍនានា ។

គំនិតផ្តួចផ្តើមពានរង្វាន់អូស្ត្រាលី នឹងៈ

- លើកទឹកចិត្តដល់អ្នកបានទទួលពានរង្វាន់អូស្ត្រាលីអោយថែរក្សានូវទំនាក់ទំនងរបស់ពួកគេជាមួយអូស្ត្រាលីតាមរយៈ ការធ្វើផែនការដ៏រឹងមាំមួយរបស់អតីតនិស្សិត ។
- ពង្រឹងកម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាលអូស្ត្រាលី ដោយដាក់អោយស្ថិតនៅក្រោមនិមិត្តសញ្ញាដ៏មានអំណាចតែមួយ ។
- គាំទ្រនិមិត្តសញ្ញាពានរង្វាន់អូស្ត្រាលី តាមរយៈយុទ្ធសាស្ត្រទីផ្សារដ៏រឹងមាំមួយ ។
- ធ្វើអោយមានការជឿជាក់ថា និស្សិតដែលទទួលផលប្រយោជន៍ពីអាហារូបករណ៍ទទួលបានបទពិសោធន៍ល្អ ក្នុងកំឡុងពេលនៃការសិក្សារបស់ពួកគេនៅអូស្ត្រាលី បើទោះបីជាមានការបង្កើនសេវាកម្មនិស្សិតក៏ដោយ ។
- បង្កើតក្រុមប្រឹក្សាភិបាលជាន់ខ្ពស់មួយ ដែលនឹងផ្តល់យោបល់ជំនាញ និងទិសដៅជាយុទ្ធសាស្ត្រស្តីពីកម្មវិធីអាហារូបករណ៍ ដែលធ្វើអោយអូស្ត្រាលីមានផលប្រយោជន៍ក្នុងរយៈពេលយូរ និងអាចធ្វើការប្រកួតប្រជែងជាមួយកម្មវិធីអាហារូបករណ៍លំដាប់ថ្នាក់ពិភពលោកដទៃទៀត ។ សមាជិកនៃក្រុមប្រឹក្សាភិបាលនឹងជ្រើសរើសចេញពីរដ្ឋាភិបាល វិស័យឯកជន និងផ្នែកឧត្តមសិក្សា ។

ថ្លែងនៅក្នុងប្រទេសសិង្ហបុរី លោកនាយករដ្ឋមន្ត្រីបានប្រកាស អំពីគំនិតផ្តួចផ្តើមពានរង្វាន់អូស្ត្រាលីនៅអាស៊ី តំណាក់កាលទី១ ។

ពានរង្វាន់អាហារូបករណ៍អូស្ត្រាលីនៅអាស៊ីលើកទី១ នឹងចាប់ផ្តើមនៅក្នុងឆ្នាំ ២០១០ ខាងមុខ ។ កម្មវិធីអាហារូបករណ៍ស្រដៀងគ្នានេះសំរាប់តំបន់ដ៏ទៃទៀត នឹងត្រូវរៀបចំឡើងនៅឆ្នាំបន្ទាប់ ។

ថ្លែងទៅកាន់អ្នកស្តាប់នៅសាកលវិទ្យាល័យសិង្ហបុរី លោកនាយករដ្ឋមន្ត្រីបានប្រកាសថា ពានរង្វាន់អាហារូបករណ៍អូស្ត្រាលីនៅអាស៊ី នឹងត្រូវបានឧបត្ថម្ភដោយមូលនិធិថ្មីចំនួន ១៨ លានដុល្លា ។

ពានរង្វាន់អាហារូបករណ៍អូស្ត្រាលី នឹងបង្ហាញអោយឃើញផងដែរនូវសមត្ថភាពរីកចំរើនខ្ពស់បំផុតរបស់អូស្ត្រាលីក្នុងវិស័យអបរំសិក្សាដោយរាប់បញ្ចូលទាំងសាកលវិទ្យាចំនួន ៨ ក្នុងចំណោមសាកលវិទ្យា

ជាប់លំដាប់ថ្នាក់កំពូលពិភពលោកចំនួន ១០០ ហើយ នេះបង្ហាញនូវការបន្តការប្តេជ្ញាចិត្តរបស់អូស្ត្រាលី ក្នុងការកសាងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសនៅក្នុងតំបន់ ។


*ទំនាក់ទំនងសារព័ត៌មាន:*

***Ms Fiona Cochaud, DHOM, 023 213 470***
**Australian Embassy Phnom Penh**

16 November 2009